ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ជម្ងឺអុតក្តាម







ការផ្សាយរបស់ក្រុមការងារផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម
កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម ASDP, ADB
Loan 2022-CAM[SF]
ឆ្នាំ 2010

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម ASDP, ADB
Loan 2022-CAM[SF]
ឆ្នាំ2010

- ឯកសារស្តីពីជំងឺឆ្លងបង្រៀនដោយលោក ផេង សុខាំ
- សារណាបញ្ចប់ការសិក្សាស្តីពីជំងឺឆ្លងដែលជួបប្រទះញឹកញាប់ លើសត្វពាហនៈក្នុងខេត្តបន្ទាយមានជ័យ របស់លោក ហាស់ ពិសិទ្ធ និស្សិតជំនាន់ទី ៦ ឆ្នាំ ១៩៩៥ ទំព័រ ទី ២៨-៣២, ៧៥-៧៦
- ឯកសារបណ្តុះបណ្តាលពេទ្យសត្វភូមិ មណ្ឌល ទី ២ របស់អង្គការ CWS
- សារណាបញ្ចប់ការសិក្សា ឆ្នាំ ១៩៩២ របស់និស្សិត ម៉ក់ សុកឌី ស្តីពីវិធានការបំបាត់ជំងឺឆ្លងសំខាន់ៗ នៃ សត្វគោ-ក្របី នៅខេត្ត កណ្តាល
- សេចក្តីណែនាំស្តីពីការពង្រឹងវិធានការទប់ស្កាត់ការឆ្លងរីករាល ដាលជំងឺអុតក្តាម ខែមិថុនា ឆ្នាំ ២០០៨ ។





# ជំងឺអុតក្តាម

Foot and Mouth Disease (FMD)

## ១- សេចក្តីផ្តើម

អុតក្តាមជាជម្ងឺរាតត្បាតគោ-ក្របីនៅក្នុងឆ្នាំ២០០៨ ជម្ងឺ អុតក្តាមបានកើតឡើងចំនួន ៦៣ លើក ក្នុងខេត្តចំនួន ១៤ ដែលរួមមាន ខេត្តបាត់ដំបង ក្រចេះ បន្ទាយមានជ័យ កំពង់ចាម តាកែវ ព្រះសីហនុ កណ្តាល សៀមរាប កំពង់ឆ្នាំង កំពត កំពង់ស្ពឺ កំពង់ធំ ស្វាយរៀង និង ខេត្តព្រៃវែងធ្វើឱ្យសត្វឈឺចំនួនជាង ២៧ ០០០ក្បាល ។

ជំងឺអុតក្តាមនេះបង្កឱ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់កម្លាំង អូសទាញរបស់ប្រជាកសិករ ដល់សេដ្ឋកិច្ចគ្រួសារ សេដ្ឋកិច្ចជាតិ ឧស្សាហកម្មចិញ្ចឹមសត្វ និងការធ្វើពាណិជ្ជកម្មសត្វក្នុងប្រទេសនានាជាច្រើន ក្នុងពិភពលោកជាពិសេសប្រទេសកម្ពុជាយើងដែលប្រើប្រាស់សត្វពាហនៈជាកំលាំងអូសទាញក្នុងវិស័យកសិកម្ម។

## ២- និយមន័យ

ជំងឺអុតក្តាមជាជំងឺមួយឆ្លងរាលដាលយ៉ាងឆាប់ជាទីបំផុតក្នុង ចំណោមជំងឺឆ្លងទាំងឡាយ ។ ជំងឺនេះកើតលើសត្វស្រុក និងសត្វព្រៃដែល

មានក្រចកជើងចង្អែកទាំងអស់មានដូចជាគោ ក្របី ប្រើស ជ្រូក ចៀម ពពែ។ល។ រោគសញ្ញារួមនៃជំងឺអុតក្តាមគឺសត្វក្តៅខ្លួន ចេញពងបែកក្នុងមាត់ លើអណ្តាត បបូរមាត់និងមានហូរទឹកមាត់ច្រើនមានដំបៅនៅលើក្រចកជើង និង ចង្អែកជើងដែលបណ្តាលឱ្យសត្វស៊ីចំណីមិនកើត និងដើរមិនរួច ។ មានអត្រាសត្វឈឺខ្ពស់ និងអត្រាសត្វងាប់ទាបតែច្រើនមានគ្រោះថ្នាក់ចំពោះសត្វក្មេង ។

## ៣- មូលហេតុ និង ការរីករាលដាលនៃជំងឺអុតក្តាម

ជំងឺអុតក្តាមកើតឡើងដោយវីរុស (Virus) ។មេរោគនេះមានប្រាំពីរប្រភេទ (O, A, C, Asia$_1$, SAT$_1$, SAT$_2$ , SAT$_3$) ហើយនៅក្នុងប្រភេទនីមួយៗ មានអនុប្រភេទផ្សេងៗច្រើនពីគ្នាទៀត ។ ម្យ៉ាងទៀតប្រភេទមេរោគទាំងអស់នេះគ្មានភាពស៊ាំនឹងជំងឺរួមគ្នាទេ ដែលជាកត្តានាំឱ្យ មានការពិបាកក្នុងការការពារ ។ ដូច្នេះក្នុងសត្វមួយក្បាលអាចកើត ជំងឺអុតក្តាមនេះច្រើនដង ។ ជំងឺអុតក្តាមដែលកើតនៅអាស៊ីភាគច្រើនបង្កឡើងដោយមេរោគប្រភេទអូ (O) ប្រភេទ Asia 1និងប្រភេទ A ។ នៅប្រទេសកម្ពុជាយើង គេបានរកឃើញមេរោគអុតក្តាមចំនួនពីរ ប្រភេទគឺ អូ ( O ) និង ប្រភេទ Asia 1 ។

**ការឆ្លងរាលដាលជំងឺបណ្តាលមកពី:**

**១. ការប៉ះពាល់ផ្ទាល់:**

- ការប៉ះពាល់ដោយផ្ទាល់រវាងសត្វដែលមានសុខភាព





**ឯកសារយោង:**

- របាយការណ៍បូកសរុបលទ្ធផលការងារផលិតកម្ម និងបសុព្យាបាល ប្រចាំឆ្នាំ ២០០៦ - ២០០៧ , ឆ្នាំ ២០០៧ - ២០០៨ របស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ។
- យុទ្ធសាស្ត្រអភិវឌ្ឍវិស័យចិញ្ចឹមសត្វនៅកម្ពុជា ដោយវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម រាជបណ្ឌិតសភា ឆ្នាំ២០០៨
- បទបង្ហាញស្តីពីការយកវត្ថុវិភាគរបស់លោកស្រី វ៉េន ធារី មន្ត្រី វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល,នាយកដ្ឋាន ផលិតកម្មនិង បសុព្យាបាល ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩
- បទបង្ហាញស្តីពីការពង្រឹងលើការអនុវត្តលិខិតបទដ្ឋាន នៃអនុក្រឹត លេខ ២៦ អនក្រ.បកចុះថ្ងៃទី ០២ មីនា ឆ្នាំ ២០០១ ស្តីពីការបង្កើត និងគ្រប់គ្រងភ្នាក់ងារសុខភាពសត្វភូមិរបស់លោក ពេច ប៉េដា(២៤/០៧/០៩)
- ខិតប័ណ្ណស្តីពី អត្ថប្រយោជន៍នៃការចាក់ថ្នាំការពារ ជំងឺអុតក្តាម របស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
- ខិតប័ណ្ណជំងឺអុតក្តាម គោលការណ៍ណែនាំភ្នាក់ងារសុខភាពសត្វភូមិរបស់នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល សហការជាមួយ OIE
- សៀវភៅបណ្តុះបណ្តាលពេទ្យសត្វភូមិ ន.ផ.ប ភ្នំពេញ ២០០០

**ប្រសិទ្ធិភាពនៃការចាក់វ៉ាក់សាំងការពារ និងរបៀបប្រើប្រាស់**

វ៉ាក់សាំងជំងឺអុតក្តាមផ្តល់ភាពស៊ាំដែលអាចការពារសត្វបានក្នុងរយៈពេលពី១០-១២ ខែ ។ រយៈពេលបង្កើតភាពស៊ាំជាមធ្យមពី ៧-១០ ថ្ងៃ ។ ដើម្បីឱ្យការចាក់វ៉ាក់សាំងការពារទទួលបានប្រសិទ្ធិភាពល្អ ត្រូវ ធ្វើឡើងក្នុងពីរជំហានៈ

- ជំហានទីមួយៈ ការចាក់លើកដំបូងនេះ ត្រូវធ្វើឡើងពីរដង ដោយមានរយៈពេលចន្លោះពីគ្នាពី ២-៤ អាទិត្យ យ៉ាងយូរបំផុត ។
- ជំហានទីពីរៈ ហៅថារំលឹកតម្រូវឱ្យយើងចាក់ពី ៦-១២ ខែ បន្ទាប់ពីចាក់លើកដំបូងអាស្រ័យទៅតាមភាពស៊ាំនៃថ្នាំការពារនីមួយៗ ។ ជាទូទៅគេត្រូវចាក់ថ្នាំឱ្យគោ-ក្របីដែលមានអាយុច្រើនជាង ៦ ខែ និងជ្រូកច្រើនជាង ៦ អាទិត្យ ។

គេអាចចាក់ថ្នាំឱ្យសត្វផើមបានដោយមានការប្រុងប្រយ័ត្ន ។





ល្អជាមួយសត្វឈឺ

- ការស៊ីចំណី និងផឹកទឹករួមគ្នា
- ការដេកនៅក្នុងទ្រុងជាមួយគ្នា

**២. ការប៉ះពាល់ដោយប្រយោល**

- ប៉ះពាល់តាមរយៈមធ្យោបាយនានាមានដូចជា សំភារៈឧបករណ៍ ស្បែកជើង សំលៀកបំពាក់ មធ្យោបាយធ្វើដំណើរ ដែលមានប្រឡាក់ប្រឡូកជាមួយមេរោគ ។
- ចលនាសត្វ និង ផលិតផលមានដើមកំណើតពីសត្វដែលមានលក្ខណៈអនាធិបតេយ្យ និងល្មើសច្បាប់ ។
- តាមរយៈខ្យល់

## ៤- រោគសញ្ញា

រយៈពេល សម្ងំ នៃមេរោគបង្កជំងឺនេះគឺ ភាគច្រើនពី ២-៧ ថ្ងៃ ។ មានករណីឆាប់រហ័សបំផុត គឺរយៈ ២ ថ្ងៃ ហើយយូរបំផុត ១៧ ថ្ងៃ ។ រោគសញ្ញា និងសភាពធ្ងន់ធ្ងរនៃជំងឺគឺអាស្រ័យទៅតាមប្រភេទវីរុស និង កម្លាំងទប់ទល់នៃប្រព័ន្ធការពាររបស់សត្វចំពោះវីរុសនោះ ដូច្នេះសត្វ ដែលពុំធ្លាប់បានឈឺជំងឺនេះនឹងមានសភាពធ្ងន់ធ្ងរជាងសត្វដែលធ្លាប់ឈឺ ជំងឺនេះជាញឹកញាប់រួចមកហើយ ។

រោគសញ្ញាដំបូងចំពោះសត្វពេញវ័យគឺ គ្រុនក្តៅ ញ័រខ្លួន មិនស៊ី

ចំណី ដើរ និងផ្លាស់ប្តូរទីកន្លែងដោយលំបាក ចំពោះសត្វក្មេងឬ ជំទង់វិញជួនកាលមានគ្រុនក្តៅយ៉ាងធ្ងន់ធ្ងរ ។

គ្រុនក្តៅក៏អន់ថយចុះទៅវិញនៅពេលមានពងទឹករងៃចាប់លេច ចេញមក ។ តាមធម្មតាពងទឹករងៃនេះច្រើនមានកើតចេញនៅបីកន្លែង គឺនៅមាត់ គល់ក្រចកជើង និងលើដោះតែជួនកាលគេសង្កេតឃើញ មានករណីលេចចេញនៅជុំវិញគល់ស្នែងទៀតផង ។

ពងដោរ និងដំបៅនៅលើបបូរមាត់ អណ្តាតបណ្តាលឱ្យមានការហៀរ ទឹកមាត់ស្អិតអន្ទាយ មានបែកពពុះមាត់ និងមានហូរទឹកមាត់យ៉ាងច្រើនធ្វើឱ្យ សត្វពិបាកស៊ីចំណី ។

ក. ផ្នែកមាត់







រៀបចំ និងបោះពុម្ពផ្សាយដោយក្រុមការងារផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម

១១. ត្រូវពង្រឹងការត្រួតពិនិត្យឱ្យបានហ្មត់ចត់នូវចលនាសត្វ និង ផលិតផលមានដើមកំណើតពីសត្វ





ថ្នាំការពារសត្វសំរាប់ប្រឆាំងនឹងជំងឺអុតក្តាម

១. ត្រូវចាក់ថ្នាំការពារជាមុន

២. ផ្តល់ព័តិមានឱ្យបានទាន់ពេលវេលាដល់បសុពេទ្យភ្នាក់ងារសុខភាព សត្វភូមិ ឬ រដ្ឋអំណាចមូលដ្ឋាននូវតំបន់ដែលកើតជំងឺ

៣. ត្រូវថែទាំសត្វឱ្យបានហ្មត់ចត់ ដូចជាការធ្វើអនាម័យមាត់ ជើង ដោះ ក្រោល ទ្រុង និងការថែបំប៉នចំណី

៤. ត្រូវក្រាលស្មៅ ឬចំបើងឱ្យសត្វដេកដើម្បីកុំឱ្យស្លោករបកស្បែក

៥. ហាមយកសត្វឈឺទៅត្រាំទឹកថ្លុក ស្ទឹង ត្រពាំង ។ល។ ដែលជាកន្លែង ប្រើប្រាស់ទឹករួម

៦. ហាមទិញ លក់ ឬ ដឹកនាំសត្វពាហនៈ ព្រមទាំងផលិតផលមានដើម កំណើតពីសត្វ ចេញ ចូល និងឆ្លងកាត់តំបន់ដែលកើតជំងឺ

៧. ត្រូវបង្ខាំងសត្វឈឺឱ្យឆ្ងាយពីសត្វជា ដោយទុកវានៅលើទួលស្អាត ស្ងួត រួចផ្តល់ចំណី និងទឹកដោយឡែកពីសត្វដទៃ

៨. សត្វដែលបានជាសះស្បើយហើយត្រូវរក្សាទុកដោយឡែករយៈពេល ៤៥ ថ្ងៃ ទើបអាចដោះលែងឱ្យរស់នៅជាមួយសត្វដទៃទៀតបាន

៩. ក្រោល ឬទ្រុងត្រូវរៀបចំឱ្យបានស្អាត គើបលាមកបញ្ចូលរណ្តៅ ឬ កប់ឱ្យជ្រៅ

១០. ត្រូវរំងាប់មេរោគដោយបាចកំបោរ ឬក្រេស៊ីលនៅក្នុងក្រោលទ្រុង និង ជំរកសត្វឈឺ



រៀបចំ និងបោះពុម្ពផ្សាយដោយក្រុមការងារផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម

សត្វដេក ឬ ឈរបង្ហូរទឹកមាត់សង្អៀតធ្មេញ។ ស្បែកស្តើងនៃមាត់ឡើងពណ៌ក្រហម និងមានពងទឹករងៃ ។ នៅអញ្ចាញធ្មេញទាំងលើ ទាំងក្រោមលើផ្ទៃក្នុងនៃថ្ពាល់ លើផ្ទៃនៃអណ្តាត គល់អណ្តាត និងបបូរមាត់ ក៏សុទ្ធសឹងមានពងទឹករងៃដូចគ្នា។ពងទឹករងៃទាំងអស់មានទំហំប៉ុនគ្រាប់សណ្តែកបាយ ឬ ប៉ុនគ្រាប់ពោត ។ សត្វពុំអាចលានអណ្តាតចេញមកក្រៅ ដើម្បីស៊ីចំណីឬអាហាររឹងបានឡើយ។ ពងទឹករងៃទាំងនេះនឹងបែកធ្លាយ ក្នុងរយៈពេល ២-៣ ថ្ងៃក្រោយ ដោយបញ្ចេញនូវទឹករងៃ បន្សល់នូវដំបៅដែលមានតែមកញ្ចែតកញ្ចូតវិញ។ប្រសិនបើគ្មានការវាយប្រហារដោយ មេរោគផ្សេងទៀត និងការរីករាលដាលទេនោះ ដំបៅនេះនឹងជាសះ ស្បើយដោយឆាប់រហ័ស។






ស្លាកស្នាមនៅលើអញ្ចាញ និងច្រមុះគោ-ក្របី

## ខ. ផ្នែកក្រចក

គេសង្កេតឃើញមានពងទឹករងៃថ្លា១ កើតឡើងយ៉ាងឆាប់រហ័ស ជាពិសេសនៅគល់ក្រចក ចង្អែកជើង និងបាតជើង ។ប្រសិនបើយកដៃស្ទាបលើកន្លែងដែលកើតពងទឹករងៃនោះនឹងមានចំហាយក្តៅហើយ សត្វកញ្ច្រោល ដោយសារការឈឺចាប់។ ក្នុងលក្ខខណ្ឌដែលមានពងទឹករងៃកើតឡើងពាសពេញសព្វកន្លែង សត្វត្រូវដេកដួលលើដីពុំអាចងើបឈរ ឬដើរបានឡើយ ។ ពងទឹករងៃ ទាំងនេះនឹងបែកធ្លាយហូរទឹករងៃបង្កជាដំបៅក្រហម ហើយឈឺរាំរ៉ៃ អាចរហូតដល់រង្គោះក្រចកទៀតផង ប្រសិនបើពុំមានការថែទាំដិតដល់ ពីសំណាក់ម្ចាស់សត្វទេ ។



រៀបចំ និងបោះពុម្ពផ្សាយដោយក្រុមការងារផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម

ត្រូវលាងជើងសត្វរាល់ថ្ងៃដោយទឹកម្ជូរ ឬទឹកក្បុង ឬសាប៊ូ ឬទឹកត្រាំសំបកស្ដៅឬទឹកត្រាំសំបកកន្ទួតព្រៃ ។ តែមុននឹងលាងត្រូវឆ្កឹះដីចេញពីចង្អែកក្រចកជើង។ ពេលលាងសំអាតរួច ត្រូវយកក្រណាត់ ទន់ ឬសំឡីជូតឱ្យស្ងួតទើបលាបថ្នាំ Betadine ឬប៉ូម៉ាតប៉េនីសេលីន ។ល។ តែបើគ្មានថ្នាំទាំងនោះទេ ត្រូវយកប្រេងសណ្តែក ឬប្រេងកន្ទក់លាយជាមួយធ្យូងបុកឱ្យម៉ត់ រួចលាបក៏បាន ឬអាចយកជ័រដើមដៃក្តាមលាបលើកន្លែងដំបៅ។

ដើម្បីជៀសវាង កុំឱ្យរុយរោមត្រូវរុំដំបៅជើងដោយក្រណាត់ ជ្រលក់ទឹកក្រេស៊ីលហើយបើមានដង្កូវត្រូវបន្តក់ប្រេងកាត ឬទឹកស្ងោរ សំបកដង្ក្បៀបក្តាម ។

### ៣. ចំពោះជំងឺអុតក្តាមនៅលើដោះ

ត្រូវលាងសំអាតចាប់ពីក្រោមពោះរហូតដល់ចន្លោះភ្លៅពិសេស កន្សោមដោះចុងដោះ ដោយទឹកម្ជូរ ឬពែរម៉ង់កាណាតមួយភាគពាន់ រួចហើយលាបប៉ូម៉ាតប៉េនីសេលីន ឬលាបប្រេងថ្លើមត្រីម៉ូរុយដើម្បី កុំឱ្យប្រេះស្បែក ឬរុយរោម ។

## ៦- វិធានការការពារ និង អនាម័យ

ដើម្បីការពារសត្វពីជំងឺអុតក្តាមយើងត្រូវអនុវត្តនូវវិធានដូច ខាងក្រោម:

តាមបទពិសោធន៍កន្លងមក ពុំមានបសុឱសថណាមួយមានប្រសិទ្ធភាព ក្នុងការព្យាបាលជំងឺអុតក្តាមទេ ។ ប៉ុន្តែលើដំបៅដែលបែកទឹកងងៃគេអាច ប្រើប្រាស់:

បែកតាម៉ីន Betadine ឬប៊្លីមេទីឡែនពែរម៉ង់កាណាត អាស៊ីតបូរិក សាច់ជូរខៀវ ស អាស៊ីតនីទ្រិច និងប៉ូម៉ាតប៉េនីសេលីន ។ ចាក់ថ្នាំពួក អង់ទីប៊ីយ៉ូទិច (សំរាប់ការឆ្លងមេរោគឱកាសនិយមពីខាងក្រៅ ) ។

## ការព្យាបាលតាមវិធីបូរាណ

### ១. ចំពោះជម្ងឺអុតក្តាមនៅមាត់

- ត្រូវឱ្យសត្វស៊ីចំណីដែលទន់ស្រួលលេបដូចជាបបរត្រកួន ស្មៅ ត្បិតជួន ឬបន្លែឆ្អិនដោយហាន់ឱ្យខ្លីៗ ឬបុកបញ្រ្ចូក
- អាចយកក្តាម និងខ្ទែងទំពាំងឬស្សីមកបុកលាយចូលគ្នាហើយ ច្រោះយកទឹកបញ្រ្ចូក
- អាចយកដើមក្រថុក សំបកស្វាយ សំបកកណ្តោល ប្រហុក និងជីនាងវងបុកបញ្ចូលគ្នាច្រោះយកទឹកបញ្រ្ចូក តែមុននឹងបញ្រ្ចូកថ្នាំទាំងនោះត្រូវលាងមាត់សត្វឱ្យបានស្អាតដោយទឹកម្ជូរក្តៅឧណ្ហៗ
- អាចយកក្រូចឆ្មារ ឬផ្លែស្ពឺជូរ ឬផ្លែអំពិលខ្ចី ឬស្លឹកអំពិលទៅជូតក្រអូមមាត់ ឬញាត់ចូលក្នុងមាត់ឱ្យសត្វស៊ីតែម្តងក៏បាន ។

### ២. ចំពោះជម្ងឺអុតក្តាមនៅគល់ក្រចក







ស្លាកស្នាមដំបៅនៅលើចង្វែកក្រចកជើងគោ-ក្របី

### គ. ផ្នែកដោះ

គេតែងសង្កេតឃើញមានទឹករងៃនៅលើកន្សោមដោះ និងចុង ដោះមេគោពិសេសមេគោដែលផ្តល់ទឹកដោះ ។ស្បែកដោះឡើងក្រហម ហើយក្តៅ ។ ក្រោយមកពងទឹករងៃក៏បែកធ្លាយ ហើយក្រៀមទៅវិញ ។

ទឹកដោះបាត់គុណភាព បរិមាណថយចុះ ហើយពេលខ្លះបាត់ចេញតែម្តង ។ ជួនកាលពងទឹករងៃអាចកើតចេញពីក្លៀកទៅពោះ ទៅដល់ យោនី ឬ ពងស្វាស ។ ចំពោះមេផើមអាចបណ្តាលឱ្យរលូតកូន ។ បើ គ្មានជំងឺផ្សេងមកលាយឡំជាមួយទេ ជំងឺនេះអាចជាសះស្បើយពីពីរទៅ បីអាទិត្យ ។ ផ្ទុយទៅវិញបើសិនជាមានជំងឺផ្សេងកើតលាយឡំជាមួយជំងឺ នេះអាចបណ្តាលឱ្យសត្វឈឺរ៉ាំរ៉ៃ ស្គមរហូតដល់ស្លាប់ក៏មាន ។ ជំងឺដែល តែងតែកើតជាមួយជំងឺអុតក្តាមនេះភាគច្រើនគឺ ជំងឺក្អករបេង ជំងឺរាគ ក្តៅជំងឺសារទឹក និង ជំងឺប៉េស្ត ។ល។



ពោងដោរ និង ដំបៅនៅលើដោះ



រៀបចំ និងបោះពុម្ពផ្សាយដោយក្រុមការងារផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម

ចំពោះសត្វជ្រូកដែលកើតជំងឺអុតក្តាម ជាញឹកញាប់ ពងទឹក រងៃច្រើនកើតមាននៅគល់ក្រចក បណ្តាលឱ្យ ជ្រុះក្រចក ជាហេតុ ដែលនាំឱ្យសត្វដើរដោយក្បាលជង្គង់ ។ ជាទូទៅ ពងទឹករងៃពុំសូវកើត មាននៅមាត់ទេ ភាគច្រើនគឺកើត នៅចុងច្រមុះ ។ចំពោះជ្រូកមេគេសង្កេត ឃើញមានពងទឹករងៃនៅលើដោះ និងក្រចកជើង ។ ហើយចំពោះកូនជ្រូកអាច ងាប់ភ្លាមៗ ។





## ៥- ការព្យាបាល

ចំពោះមុខមានការខ្វះខាតថ្នាំព្យាបាលសត្វ ឬ បសុឱសថសម័យ ហេតុ នេះដើម្បីកាត់បន្ថយការខាតបង់ និងហានិភ័យដែលបង្កឡើងដោយជម្ងឺ អុតក្តាម នាយកដ្ឋានផលិតកម្មនិងបសុព្យាបាលបានប្រមូលបទពិសោធន៍អនុវត្តជាក់ ស្តែងប្រើប្រាស់វត្ថុធាតុធម្មជាតិសំរាប់ព្យាបាលដំបៅ និងវិធានបសុពេទ្យមួយចំនួន ដើម្បីជាជំនួយដល់ប្រជាកសិករក្នុងការថែទាំសត្វនិងព្យាបាលដំបៅនៃជម្ងឺអុតក្តាម ។